雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团
No.154

ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី 26 លេខ 7646 ថ្ងៃសុក្រ ទី01 ខែមិថុនា ឆ្នាំ 2018

ក្រុងប៉េកាំង និងក្រុងភ្នំពេញបង្កើតសម្ព័ន្ធមេត្រីភាព

柬埔寨王国首都金边市
与中华人民共和国首都北京市
建立友好城市关系
2018年 21日

ពិធីចុះហត្ថលេខាចងសម្ព័ន្ធភាពរវាងរដ្ឋធានីប៉េកាំង និងរាជធានីភ្នំពេញ (រូបថត ដោយ Ding Feng)

កិច្ចព្រមព្រៀងស្ដីពីការបង្កើតសម្ព័ន្ធមេត្រីភាពរវាងទីក្រុងប៉េកាំងនិងទីក្រុងភ្នំពេញបានត្រូវចុះហត្ថលេខាជាផ្លូវការនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០១៨ នៅឯរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា។

តាមកិច្ចព្រមព្រៀងនេះ ឈរលើគោលការណ៍ដែលផ្ដល់ផលប្រយោជន៍ដល់គ្នាទៅវិញទៅមកក្រុងប៉េកាំង និងក្រុងភ្នំពេញ នឹងបង្កើនការផ្លាស់ប្ដូរ និងកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ចពាណិជ្ជកម្ម ការពារបរិស្ថានទេសចរណ៍ បច្ចេកវិជ្ជា វប្បធម៌ អប់រំ កីឡា សុខាភិបាល និងធនធានមនុស្សជាដើម ដើម្បីជំរុញការអភិវឌ្ឍដោយរួមគ្នា។

នៅថ្ងៃដដែលនោះ សភាពាណិជ្ជកម្មក្រុងប៉េកាំងប្រទេសចិននៅប្រទេសកម្ពុជាបានត្រូវបង្កើតឡើងជាផ្លូវការ។ តាមការឧទ្ទេសនាមបានឱ្យដឹងថា ក្រុងប៉េកាំងមានខណ្ឌចំនួន១៦ និងមានផ្ទៃក្រឡា១.៦៤១ម៉ឺនគីឡូម៉ែត្រការ៉េ ។ គិតមកដល់ចុងឆ្នាំ២០១៧ ក្រុងប៉េកាំងមានប្រជាជនអចិន្ត្រៃយ៍ ២១,៧លាននាក់ ។ តាមទិន្នន័យពីវេបសាយសាលារដ្ឋបាលរាជធានីភ្នំពេញបានឱ្យដឹងថា ក្រុងភ្នំពេញមានប្រជាជនប្រមាណ១,៥លាននាក់ និងមានផ្ទៃក្រឡា៦៧៨គីឡូម៉ែត្រការ៉េដែលជាទីក្រុងធំជាងគេរបស់ប្រទេសកម្ពុជា៕

ដោយម៉ៅ ភីងហ៊ី (ស៊ីនហួ ចិន)

ស្ថាប័នគយក្រុងគុនមីងផ្ដល់ការងាយស្រួលដល់ការឆ្លងដែនដើម្បីរៀបចំពិព័រណ៍ចិន-អាស៊ីខាងត្បូងឱ្យបានជោគជ័យ

តាមការណែនាំពីអ្នកទទួលខុសត្រូវពាក់ព័ន្ធនៃស្ថាប័នគយក្រុងគុនមីងបានឱ្យដឹងថា ស្ថាប័នគយក្រុងគុនមីងបានធ្វើការពិនិត្យរួមចំពោះវត្ថុតាំងពិព័រណ៍ក្នុងពិព័រណ៍ចិន-អាស៊ីខាងត្បូង ចំណែកវត្ថុតាំងពិព័រណ៍ផ្សេងៗអាចត្រូវផ្ដល់កិច្ចធានាដោយអ្នករៀបចំ ឬអ្នកស្ដីទីតែម្ដង ។ តាមសេចក្ដីសម្រេចរបស់ស្ថាប័នគយពាណិជ្ជករនិងអ្នកស្ដីទីអាចលើកសំណើជូនស្ថាប័នគយទុកជាមុនដោយឈរលើមូលដ្ឋានបញ្ជី ឈ្មោះនៃវត្ថុតាំងពិព័រណ៍ដើម្បីទទួល ការពិនិត្យពីស្ថាប័នគយនៅមជ្ឈមណ្ឌលសន្និសីទនិងពិព័រណ៍អន្តរជាតិបឹងទាន ឃើក្រុងគុនមីង ។ វិធានការនេះនឹងអាចបង្កើនល្បឿននៃការបំពេញបែបបទឆ្លងដែននិងបន្ថយចំណាយនៃការឆ្លងដែន ។

តាមប្រភពព័ត៌មានបានឱ្យដឹងថា នៅពេលរៀបចំពិព័រណ៍ចិន-អាស៊ីខាងត្បូង ស្ថាប័នគយក្រុងគុនមីងផ្ដល់អាទិភាពដល់ពាណិជ្ជករដែលចូលរួមក្នុងពិព័រណ៍នេះ ដោយបានបង្កើតច្រកឆ្លងដែនរហ័សដើម្បីសម្រួលដល់ការបំពេញបែបបទឆ្លងដែនរបស់មនុស្សនិងសម្ភារៈដែលពាក់ព័ន្ធនឹងពិព័រណ៍ចិន-អាស៊ីខាងត្បូងនេះ ។ ស្ថាប័នគយក្រុងគុនមីង បានអនុវត្តន៍យន្តការការងារ "៥បូក២" (៧ថ្ងៃ) និងរបបណាត់ពេលបំពេញបែបបទឆ្លងដែនទាំង២៤ម៉ោង ហើយបានបង្កើតឃ្លាំងស្តុកបណ្តោះអាសន្ននៅកន្លែងតាំងពិព័រណ៍ដើម្បីផ្ដល់ការងាយស្រួលដល់សហគ្រាសដែលចូលរួមពិព័រណ៍ហើយក៏អាចបំពេញតម្រូវការការងាររបស់ស្ថាប័នគយដែរ។

អ្នកទទួលខុសត្រូវនៃស្ថាប័នគយក្រុងគុនមីង បានធ្វើបទឧទ្ទេសនាមថា តាមសំណើរបស់ពាណិជ្ជករ ឬអ្នកស្ដីទី ការពិនិត្យវត្ថុតាំងពិព័រណ៍និងការរៀបចំពិព័រណ៍អាចធ្វើឡើងដោយព្រមពេលជាមួយគ្នា។ ជាពិសេសស្ថាប័នគយនឹងទៅពិនិត្យវត្ថុតាំងពិព័រណ៍នៅពន្ធាពិព័រណ៍តែម្ដង ។ វិធានការនេះនឹងអាចផ្ដល់ការងាយស្រួលដល់ពាណិជ្ជករដែលចូលរួមពិព័រណ៍ ព្រមទាំងកាត់បន្ថយចំណាយរបស់ពាណិជ្ជករ ។ ដើម្បីបំពេញការងារនេះឱ្យបានល្អប្រសើរ ស្ថាប័នគយនឹងផ្ដល់ធនធានមនុស្សជំនាញឱ្យទាន់ពេលវេលាចាត់ចែងឱ្យមន្ត្រីប្រចាំការទៅធ្វើកានៅកន្លែងតាំងពិព័រណ៍ដើម្បីទទួលខុសត្រូវចំពោះការបំពេញបែបបទពាក់ព័ន្ធព្រមទាំងផ្ដល់សេវាកម្មប្រឹក្សាយោបល់ដល់ពាណិជ្ជករក្រុមហ៊ុនស្ដីទី និងសាធារណជនតាមរយៈច្រកអន្តរជាតិផ្សេងៗកន្លែងពិគ្រោះយោបល់ក្នុង ពិព័រណ៍ "Hot-line ១២៣០៦" និងវេបសាយនៃស្ថាប័នគយជាដើម ៕ **ដោយលីវ ជឺយូ**

បទពិសោធន៍អភិវឌ្ឍន៍របស់ក្រុងសិនជិនទទួលការចាប់អារម្មណ៍នៅប្រទេសកម្ពុជា

អ្នកទទួលខុសត្រូវនៃការិយាល័យវិនិយោគនិងផែនការខេត្តព្រះសីហនុ បានប្រាប់អ្នកកាសែតនៃទីភ្នាក់ងារព័ត៌មានស៊ីហ្វូចិនថា យើងត្រូវខិតខំរៀនបទពិសោធន៍ពីក្រុងសិនជិន ដូច្នេះខ្ញុំបានកត់ត្រាខ្លឹមសារសំខាន់ៗលើក្រដាស៥សន្លឹក ។ លោកបានធ្វើដំណើរមកដល់ភ្នំពេញដើម្បីចូលរួមវេទិកាចែករំលែកគ្នាអំពីបទពិសោធន៍អភិវឌ្ឍន៍របស់ក្រុងសិនជិនដែលរៀបចំដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

វេទិកានេះរៀបចំដោយមូលនិធិដើម្បីការផ្លាស់ប្តូរនិងកិច្ចសហប្រតិបត្តិការអន្តរជាតិក្រុងសិនជិនអង្គការអភិវឌ្ឍន៍ឧស្សាហកម្មនៃអង្គការសហប្រជាជាតិនិងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីធ្វើបទបង្ហាញជូនមន្ត្រីរាជការ និងតំណាងមកពីតំបន់សេដ្ឋកិច្ចពិសេសនៃប្រទេសកម្ពុជានូវបទពិសោធន៍អភិវឌ្ឍន៍របស់ក្រុងសិនជិននិងពង្រឹងកិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរអំពីការអភិវឌ្ឍសេដ្ឋកិច្ចនិងការគ្រប់គ្រងសង្គមជាដើម ។

លោកប្រធានមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវគោលនយោបាយកម្ពុជាបានប្រាប់អ្នកកាសែតថាវេទិកានេះបានដាក់តាំងបង្ហាញនូវដំណើរអភិវឌ្ឍន៍របស់ក្រុងសិនជិនក្នុងរយៈពេលរាប់សិបឆ្នាំកន្លងទៅនោះ ។ អ្វីដែលធ្វើឱ្យខ្ញុំចាប់អារម្មណ៍ខ្លាំងជាងគេនោះ គឺថ្នាក់ដឹកនាំរបស់ប្រទេសចិនបានកំណត់ផែនការអភិវឌ្ឍន៍លម្អិតហើយនឹងខិតខំប្រឹងប្រែងដើម្បីសម្រេចបាននូវពាក្យសន្យារបស់ខ្លួន ។ នេះគឺជាចំណុចសំខាន់ដែលយើងទាំងអស់គ្នាត្រូវតែខិតខំរៀនសូត្រ ។

លោកឆាវ ឈុង អគ្គលេខាធិការនៃមូលនិធិដើម្បីការផ្លាស់ប្តូរនិងកិច្ចសហប្រតិបត្តិការក្រុងសិនជិនបានមានប្រសាសន៍ថា តាមរយៈ "គម្រោងចែករំលែកគ្នាអំពីបទពិសោធន៍អភិវឌ្ឍន៍របស់ក្រុងសិនជិន" បទពិសោធន៍នៃការអភិវឌ្ឍតំបន់ពិសេសរយៈពេល៥០ឆ្នាំរបស់ក្រុងសិនជិននឹងត្រូវបានបូកសរុបនិងផ្សព្វផ្សាយឱ្យបានទូលំទូលាយដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមនៃប្រទេសកម្ពុជា ៕

ដោយម៉ៅ ភីងហ៊ី(ស៊ីនហួចិន)

ក្រុមហ៊ុន ZTO សាងសង់មជ្ឈមណ្ឌលដឹកជញ្ជូននិងចែកចាយទំនិញធំជាងគេនៅប្រទេសកម្ពុជា

ស្វាយរៀង
柴桢
កំពត
贡布
暹粒

បុគ្គលិកម្នាក់រូបកំពុងតែរៀបចំកញ្ចប់បញ្ញើនៅមជ្ឈមណ្ឌល ចែកចាយ (រូបថតដោយYu Jiangning)

ពេលថ្មីៗនេះ ក្រុមហ៊ុនដឹកជញ្ជូននិងចែកចាយទំនិញ ZTOបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្ដីពីកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រជាមួយប្រៃសណីយ៍ជាតិកម្ពុជានិងក្រុមហ៊ុនអេឡិចត្រូនិក ប្រៃសណីយ៍កម្ពុជាដើម្បីបង្កើតក្រុមហ៊ុន ZTO (កម្ពុជា) ។ ទន្ទឹមនឹងនេះមជ្ឈមណ្ឌលដឹកជញ្ជូននិងចែកចាយទំនិញ ZTO ដែលជាមជ្ឈមណ្ឌលដឹកជញ្ជូននិងចែកចាយទំនិញធំជាងគេនៅប្រទេសកម្ពុជាបានត្រូវសាងសង់និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅរាជធានីភ្នំពេញ ។

លោកចាំង វៃ អគ្គនាយកនៃក្រុមហ៊ុន ZTO (កម្ពុជា) បានបញ្ជាក់ថា ក្រោមការគាំទ្រពីទីស្នាក់ការពាណិជ្ជកម្មខេត្តយូនណានប្រចាំនៅរាជធានីភ្នំពេញ យើងខ្ញុំបានបង្កើតក្រុមហ៊ុនថ្មីដោយបានប្រើប្រាស់រយៈពេលមិនដល់មួយឆ្នាំ។ សព្វថ្ងៃក្រុមហ៊ុនបានចាប់ដំណើរការនូវអាជីវកម្មដឹកជញ្ជូនទំនិញក្នុងប្រទេសកម្ពុជានិងអាជីវកម្មដឹកជញ្ជូនទំនិញរវាងប្រទេសចិន និងកម្ពុជា ហើយបានបង្កើតកន្លែងចែកចាយទំនិញច្រើននៅប្រទេសកម្ពុជា។

លោក ប្រាក់ គៀវ៉ាវុធ អនុប្រធានប្រៃសណីយ៍កម្ពុជាបានមានប្រសាសន៍ថា ខ្ញុំមានភាពសប្បាយរីករាយដែលបានឃើញក្រុមហ៊ុន ZTO របស់ប្រទេសចិនមកជួយអភិវឌ្ឍន៍វិស័យដឹកជញ្ជូន និងចែកចាយទំនិញនៅប្រទេសកម្ពុជា ដោយបាននាំមកនូវបច្ចេកវិជ្ជាថ្មីៗសេវាកម្មល្អប្រសើរ និងគុណភាពខ្ពស់។ ប្រៃសណីយ៍កម្ពុជាយល់ឃើញថា ក្រុមហ៊ុន ZTO ជាដៃគូសហប្រតិបត្តិការល្អមួយដែលនឹងអាចផ្ដល់ដល់ប្រជាជននៃប្រទេសកម្ពុជានូវសេវាកម្មដឹកជញ្ជូន និងចែកចាយ ទំនិញពេញលក្ខណៈ៕ **ដោយយូ ជាំងនីង**

ទិវាទេសចរណ៍វប្បធម៌ខ្លុយឃ្លោក ស្រុកលាំងហ៊ី ប្រទេសចិន ឆ្នាំ២០១៨ នឹងសម្ពោធនៅខែសីហា

ក្នុងអំឡុងពេលពីថ្ងៃទី៨ ដល់ទី១០ ខែសីហា ឆ្នាំ២០១៨ ទិវាទេសចរណ៍វប្បធម៌ខ្លុយឃ្លោកស្រុកលាំងហ៊ី ប្រទេសចិន ឆ្នាំ២០១៨ នឹងរៀបចំនៅស្រុកលាំងហ៊ីនៃខេត្តយូនណាន។ ក្នុងឱកាសនោះ តន្ត្រីករផ្លុំខ្លុយឃ្លោកល្បីឈ្មោះជាតិនិងអន្តរជាតិនឹងជួបជុំគ្នានៅស្រុកលាំងហ៊ីដែលបានត្រូវគេសន្មតជាស្រុកកំណើតខ្លុយឃ្លោក។ ទន្ទឹមនឹងនេះ ការប្រកួតផ្លុំខ្លុយឃ្លោកនឹងត្រូវរៀបចំដោយព្រមពេលជាមួយគ្នា។

ស្រុកលាំងហ៊ីជាប្រភពដើមនៃវប្បធម៌ "ខ្លុយឃ្លោក" ហើយក៏ជាកន្លែងនិពន្ធបទភ្លេងខ្លុយឃ្លោកល្បីឈ្មោះដ៏ច្រើនរួមមានបទ "ភ្លេងបុរាណ" និង "ដើមឫស្សីជ្រៅ" ជាដើម។ តាមប្រភពព័ត៌មានបានឱ្យដឹងថា ការប្រកួតផ្លុំខ្លុយឃ្លោកស្រុកលាំងហ៊ីបានរៀបចំបីលើកហើយ ។ ឆ្នាំនេះការប្រកួតនេះបានបែងចែកជា១១ផ្នែកដោយអាស្រ័យលើក្រុមបេក្ខជន បេក្ខនារីដែល ចូលរួមការប្រកួតនេះ។ផ្នែកនីមួយៗសុទ្ធតែមានពានរង្វាន់លេខ១ លេខ២ និងលេខ៣ ព្រមទាំងរង្វាន់ឆ្នើមមួយចំនួន ។ ឱ្យតែចុះឈ្មោះចូលរួមការប្រកួតនេះក៏អាចទទួលបាននូវរង្វាន់និងសញ្ញាបត្រ។ គួរបញ្ជាក់ថា ប្រាក់រង្វាន់នៃការប្រកួតនេះមានចំនួន សរុប២៥ម៉ឺនយ័ន ។

មិនតែប៉ុណ្ណោះ ក្នុងទិវាទេសចរណ៍វប្បធម៌នេះ នៅមានសកម្មភាពមួយចំនួនទៀត ដូចជាការប្រកួតវត្ថុសិប្បកម្មឃ្លោក ពិព័រណ៍វត្ថុសិប្បកម្មឃ្លោកចិន ពិព័រណ៍ចង្កៀងឃ្លោក ពិព័រណ៍ម្ហូបឆ្ងាញ់លាំងហ៊ី និងពិព័រណ៍កសិផលគុណភាពខ្ពស់ជាដើម។

ឆ្នាំនេះ ទិវាទេសចរណ៍វប្បធម៌ ខ្លុយឃ្លោក ស្រុកលាំងហ៊ី ប្រទេសចិន ឆ្នាំ២០១៨ នឹងរៀបចំនៅស្រុកលាំងហ៊ី នៃខេត្តយូនណាន ពីថ្ងៃទី៨ ដល់២០ ខែ សីហា (រូបថតដោយការិយាល័យ ស្រុកលាំងហ៊ី)